BMI0090

# សម្ភាសន៍ជាមួយឈ្មោះ ប៉ាន់ ប៊ុននី ភេទប្រុស អាយុ៥០ឆ្នាំ

## មុខងារសម័យមុនៈ កសាងប្រឡាយ

## សព្វថ្ងៃរស់នៅភូមិជន្លៀសដៃ ឃុំគោកកឋិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ស៊ិន សុធីតា

## ០០:៣៨:០០

## ១៧ទំព័រ

ធីតាៈ ពូឈ្មោះអីដែរ?

ប៉ាន់ៈ ខ្ញុំឈ្មោះ ប៉ាន់ ប៊ុននី ។

ធីតាៈ អាយុប៉ុន្មាន?

ប៉ាន់ៈ អាយុ៥០ ។

ធីតាៈ ស្រុកកំណើត?

ប៉ាន់ៈ ជំលៀសដៃ ។

ធីតាៈ នៅភូមិហ្នឹងឃុំហ្នឹងហើយបច្ចុប្បន្នក៏នៅភូមិហ្នឹងដែរ?

ប៉ាន់ៈ បាទ! ភូមិជំលៀសដៃ ឃុំគោកគាឃិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ធីតាៈ ឪពុកម្ដាយពូឈ្មោះអីគេ?

ប៉ាន់ៈ ឪពុកម្ដាយ?

ធីតាៈ ចា៎! ឪពុកពូឈ្មោះអី?

ប៉ាន់ៈ ឪពុកឈ្មោះ ប៉ាន់ ប៉ាត ។

ធីតាៈ ឥលូវគាត់ស្លាប់ហើយមែនទេ?

ប៉ាន់ៈ បាទ!

ធីតាៈ ម្ដាយ?

ប៉ាន់ៈ ម្ដាយឈ្មោះ បឹក ឡាយ ។

ធីតាៈ គាត់ស្លាប់ដែរមែនពូ?

ប៉ាន់ៈ បាទ!

ធីតាៈ ចុះកាលពីមុនគាត់ធ្វើអីគេ?

ប៉ាន់៖ ឪពុកខ្ញុំកាលពីមុនគាត់ធ្វើទាហានដែរ ទាហានសម័យរាស្ត្រនិយមណោ៎ះ។

ធីតា៖ សម័យសង្គមរាស្ត្រ?

ប៉ាន់៖ បាទ!

ធីតា៖ ធ្វើអីគេកាលហ្នឹង?

ប៉ាន់៖ គាត់ធ្វើទាហាន។

ធីតា៖ ទាហានខាងអី?

ប៉ាន់៖ ទាហាន លន់ នល់។

ធីតា៖ គាត់ជាអ្នកដឹកនាំគេឬក៏ម៉េច?

ប៉ាន់៖ គាត់ជាអ្នកដឹកនាំគេប៉ុន្តែមិនថ្នាក់ខ្ពស់ទេ។

ធីតា៖ ថ្នាក់ដឹកនាំដូចថាខាងអីគេ? ដូចថាមានជំនាញខាងផ្នែកអីគេខ្លះ?

ប៉ាន់៖ ខាងកងទ័ព។

ធីតា៖ កងទ័ពម៉ោពីខាងណា?

ប៉ាន់៖ កងទ័ពនៅក្នុងក្រុមរបស់គាត់ហ្នឹងឯង។ ឧទាហរណ៍ថាយើងរើសកងទ័ពម៉ោអញ្ចឹងណោ៎ះ ហើយគាត់ជាអ្នកដឹកនាំកងម្នាក់ដែរ។

ធីតា៖ មួយកងមានគ្នាប៉ុន្មាននាក់?

ប៉ាន់៖ មាន៣០នាក់។

ធីតា៖ ចុះគាត់ក្រៅពីធ្វើទាហានគាត់ធ្វើអីទៀត?

ប៉ាន់៖ អត់មានធ្វើអីទៀតទេ។

ធីតា៖ ធ្វើតែទាហានលន់ នល់ ហ្នឹង?

ប៉ាន់៖ បាទ! ឈប់ពីនោះម៉ោដល់សម័យ៣ឆ្នាំ។

ធីតា៖ សម័យ៣ឆ្នាំ?

ប៉ាន់៖ បាទ!

ធីតា៖ កាលឆ្នាំ៧៥អង្គការជំលៀសគាត់ទៅណា?

ប៉ាន់៖ អង្គការជំលៀសគាត់ទៅខាងបេងបត់។

ធីតា៖ បេងបត់?

ប៉ាន់៖ បាទ!

ធីតា៖ បេងបត់ហ្នឹងនៅណា?

ប៉ាន់ៈ នៅខាងកើតភ្នំស្រុក ។

ធីតាៈ ឃុំអីគេ?

ប៉ាន់ៈ នៅនោះមិនដឹងគេប្រើឃុំអីទេ ។

ធីតាៈ ស្រុកភ្នំស្រុក?

ប៉ាន់ៈ បាទកាលសម័យ៧៩ គេជំលៀសទៅហ្នឹង ។

ធីតាៈ ទៅទាំងគ្រួសារតែម្តង?

ប៉ាន់ៈ បាទទៅទាំងភូមិទៅទាំងគ្រួសារតែម្តង ។

ធីតាៈ មានប៉ុន្មានគ្រួសារ មានប៉ុន្មានភូមិ?

ប៉ាន់ៈ កាលនោះគ្មានទៅបានរាប់ទេ ។

ធីតាៈ អាចប៉ាន់ស្មានបានទេថាប្រហែលប៉ុន្មានរយនាក់ទៅ?

ប៉ាន់ៈ មិនដល់រយទេប្រហែលជា៩០,៦០ហ្នឹងឯងព្រោះភូមិកាលនោះមិនទាន់រីកចំរើនផង ។

ធីតាៈ ជំលៀសទៅរស់នៅសហករណ៍អីគេ?

ប៉ាន់ៈ មិនទាន់រៀបចំទេកាលសម័យនោះ ។

ធីតាៈ កាល៧៩ហ្នឹងអត់ទាន់រៀបចំទេ?

ប៉ាន់ៈ បាទ ។

ធីតាៈ អញ្ចឹងផ្លើលទៅខាងណាវិញ?

ប៉ាន់ៈ យើងគេជំលៀសចេញគេជំលៀសនោះរួចហើយប្រហែលជាយើង៧៥ដែលចប់ពីនោះម៉ោបាន ៧៩,៧៥ ដល់ហើយចុង៧៦នេះចូលម៉ោក្នុងភូមិវិញ ។

ធីតាៈ ដូចថាពេលជំលៀស៩០គ្រួសារហ្នឹងអត់ទាន់មានរៀបចំជាសហករណ៍អីទេ?

ប៉ាន់ៈ អត់ទាន់រៀបចំបានទេ ។

ធីតាៈ អាហ្នឹងនៅក្រុមបង្កាស់ដៃនៅឡើយ?

ប៉ាន់ៈ កាលនោះនៅក្នុងដែលយើងហៅថាប្រទាញប្រទង់ណ៎ ។

ធីតាៈ កាល៧៦មានការប្រទាញប្រទង់ខ្លាំងមែន?

ប៉ាន់ៈ បាទ ។

ធីតាៈ ប្រទាញប្រទង់ម៉េចខ្លះទៅ?

ប៉ាន់ៈ ប្រទាញប្រទង់ដោយសារសង្គ្រាម ។

ធីតាៈ ដោយសារសង្គ្រាម?

ប៉ាន់៖ បាទ ។ កាលសង្គ្រាមលន់ នល់ ជាមួយខ្មែរក្រហមហ្នឹងឯងដូចជាយាកកុនណា៎កាលសម័យនោះ ។

ធីតា៖ ចា៎ ។ កាល៧៦មានទាហានយាកកុនដែរ?

ប៉ាន់៖ មានតើ ។ តែសម័យនោះវាមិនទាន់ចប់ចូលសម័យរបបទិញ ចុង៧៥,៧៦ ដល់ចូលចប់ម៉ោ ហើយបានប្រជាជនចូលម៉ោរស់នៅក្នុងភូមិវិញ ។

ធីតា៖ កាល៧៦មានយាកកុនដែរ កាល៧៥ដល់៧៩ហ្នឹងសម័យខ្មែរក្រហមតើ?

ប៉ាន់៖ និយាយរួមទៅយើងមិនបានចាប់អារម្មណ៍លើឆ្នាំទេ ។ កាលឆ្នាំនោះវាលំបាកប្រទាញប្រទង់ ហើយខ្ញុំអារឿងឆ្នាំរឿងអីខ្ញុំមិនដែលកុហកទេ ។

ធីតា៖ អញ្ចឹងទាហានយាកកុនហ្នឹងម៉ោពីខាងណា?

ប៉ាន់៖ ម៉ោពីខាងកើតហ្នឹងឯង ។

ធីតា៖ ខាងកើតហ្នឹងនៅខាងណាវិញ?

ប៉ាន់៖ នៅយើងថាយើងធ្វើសង្គ្រាមយើងធ្វើដេញពីខាងកើតម៉ោណា៎ ។

ធីតា៖ ដេញពីខាងភូមិឃុំម៉ោពីស្រុកណាវិញ? គេហៅតំបន់អីគេ?

ប៉ាន់៖ ខាងសៀមរាប ។

ធីតា៖ តំបន់សៀមរាប?

ប៉ាន់៖ បាទ ។ កាលនោះសង្គ្រាមអត់មានម៉ោពីខាងលិចទេម៉ោតែពីខាងកើតកាលសម័យនោះ ។

ធីតា៖ កាលហ្នឹងម៉េចបានម៉ោអញ្ចឹង?

ប៉ាន់៖ សង្គ្រាមសម័យសង្គ្រាមអត់មានធ្វើពីលិចទៅកើតទេ ធ្វើពីកើតដេញម៉ោលិច ។

ធីតា៖ ធ្វើពីសៀមរាបដេញទៅថៃវិញ?

ប៉ាន់៖ បាទ ។ គឺចប់នៅត្រឹមព្រំប្រទល់ថៃហ្នឹងហ្នង ម៉ោចប់នៅថ្មពួកយើងនេះ ។

ធីតា៖ ចុះពូមានចូលរួមនៅក្នុងហ្នឹងដែរអត់?

ប៉ាន់៖ អត់មានចូលរួមទេខ្ញុំជាប្រជាជនសុទ្ធសាទ កាលនោះខ្ញុំមិនទាន់បានគ្រួសារទេ ខ្ញុំកាលនោះអាយុ ប្រហែលជា១៥ឆ្នាំ ។

ធីតា៖ អាយុ១៥ទេ?

ប៉ាន់៖ បាទ ។ ដល់រួចហើយគេចូលម៉ោបានរៀបចំនៅក្នុងភូមិ ក្នុងឆ្នាំនោះខ្ញុំមិនដឹងថាឆ្នាំណាទេដូចជា ដាច់ឆ្នាំ៧៥ចូលឆ្នាំ៧៦ណា៎ ដល់ហើយបានគេរៀបចំនៅក្នុងភូមិជាសហករណ៍ ជាក្រុម ។

ធីតា៖ ភូមិអីគេ?

ប៉ាន់:   ភូមិជិលៀសដៃហ្នឹងឯង ។  ម៉ោរៀបចំជាក្រុមជាភូមិអញ្ចឹងហើយបានយើងចាត់ជាក្រុមជាពួក ។

ធីតា:   សហករណ៍ហ្នឹងអ្នកណាគេជាអ្នកគ្រប់គ្រង?

ប៉ាន់:   គឺអ្នកនៅក្នុងភូមិយើងនេះឯង ។

ធីតា:   ពូមានចាំឈ្មោះទេពូ?

ប៉ាន់:   សហករណ៍ហ្នឹងឈ្មោះតាវឿន ។

ធីតា:   គាត់ម៉េចដែរកាចឬក៏ស្លូត?

ប៉ាន់:   គាត់ធម្មតាមិនកាចហើយក៏ស្លូតដែរ ។

ធីតា:   ការដឹកនាំរបស់គាត់មធ្យម?

ប៉ាន់:   បាទ ។

ធីតា:   លក្ខណៈមធ្យមហ្នឹងមានអីគេខ្លះ?

ប៉ាន់:   លក្ខណៈមានប្រើធម៌ត្រជាក់មានប្រើធម៌ក្ដៅ  ខុសធ្វើតាមខុស  ហើយត្រូវធ្វើតាមត្រូវ ។

ធីតា:   ចុះពូត្រូវអង្គការចាត់តាំងទៅខាងណាវិញ?

ប៉ាន់:   ខ្ញុំអង្គការចាត់តាំងទៅខាងចល័ត ។

ធីតា:   កងចល័ត?

ប៉ាន់:   បាទ ។

ធីតា:   កងចល័តនៅណាវិញ?

ប៉ាន់:   នៅក្នុងភូមិនេះដែរតែគេចល័តនៅខាងភូមិបន្ទាយឆ្មា ។

ធីតា:   អ៊ំពូទៅខាងភូមិបន្ទាយឆ្មា?

ប៉ាន់:   បាទ ។  ទៅលើកទំនប់នៅខាងហ្នឹង ។

ធីតា:   មានគ្នាប៉ុន្មាននាក់នៅហ្នឹង?

ប៉ាន់:   កាលនោះលើកជាស្រុក ។

ធីតា:   នៅភូមិបន្ទាយឆ្មា  ម៉េចបានពូទៅដល់ភូមិបន្ទាយឆ្មា?

ប៉ាន់:   ស្រុកថ្មពួក ។

ធីតា:   ស្រុកថ្មពួក?

ប៉ាន់:   បាទ ។  អាហ្នឹងគេហៅចល័តស្រុក ។  ធ្វើទំនប់នៅអាងដើងគ្រោះយើងហ្នឹង ។

ធីតា:   នៅអាងដើងគ្រោះ?

ប៉ាន់:   បាទ ។  កាលនោះបើកវគ្គដំបូង  អាងដើងគ្រោះដំបូងគេបង្ហស់ ។

ធីតាៈ ប្រជាជនម៉េចដែរនៅហ្នឹង?

ប៉ាន់ៈ ប្រជាជនរឿងរស់នៅធម្មតាទេ ហើយការហូបចុកគឺហូបបបរ ។

ធីតាៈ នៅបន្ទាយឆ្មាមានហូបបបរដែរ? .

ប៉ាន់ៈ ហូបសម័យនោះទូទៅ ។ តាំងពីចូលម៉ោនៅសហករណ៍គឺហូបបបររហូត ។

ធីតាៈ ហូបបបររហូត?

ប៉ាន់ៈ បាទ៣ឆ្នាំ៨ខែមិនដែលមានបាយហូបទេ ។

ធីតាៈ ហេតុអីបានជាអត្តការជំលៀសពូទៅខាងបន្ទាយឆ្មាវិញ?

ប៉ាន់ៈ គេអត់បានជំលៀសទេ គេចាត់ជាពួកជាក្រុម ។

ធីតាៈ ហ្នឹងអើយ ។ ពូខាងក្រុមទីប៉ុន្មាន? គេមានចែកជាក្រុមអីទេ?

ប៉ាន់ៈ កាលនោះអត់មានលេខទេ ។ ដូចថាក្រុមចល័តហើយកាលសម័យនោះវាយុទ្ធជនណា៎ ក្នុងមួយភូមិនេះមានយុទ្ធជនប៉ុន្មាននាក់ ដូចថា២០នាក់អញ្ចឹងគេធ្វើយាមមួយក្រុម ដល់ហើយគេដកកម្លាំងថាក្នុងភូមិនេះគេសុំកម្លាំងប៉ុន្មាន ៣នាក់ដើម្បីទៅក្នុងស្រុកដើម្បីទៅលើកទំនប់ ។

ធីតាៈ ចា៎ ។ ទៅលើកទំនប់នៅអាងដើងគ្រោះហ្នឹងមែន?

ប៉ាន់ៈ បាទ ។

ធីតាៈ នៅស្រុកថ្មពួក?

ប៉ាន់ៈ បាទ ។

ធីតាៈ មានប្រជាជនស្លាប់អត់នៅហ្នឹង? រ

ប៉ាន់ៈ អារឿងស្លាប់មិនដែលអត់ទេ ។

ធីតាៈ ស្លាប់ច្រើនទេ?

ប៉ាន់ៈ ច្រើនដែរហ្នឹង ។

ធីតាៈ នៅទំនប់ហ្នឹងពីណាគេអ្នកគ្រប់គ្រង?

ប៉ាន់ៈ មិនដឹងទេ ។

ធីតាៈ អត់ដឹងទេ?

ប៉ាន់ៈ បាទ ។

ធីតាៈ ចុះពូមានដែលឃើញគេសម្លាប់មនុស្សផ្ទាល់ភ្នែកទេ?

ប៉ាន់ៈ ធ្លាប់ឃើញដែរ ។

ធីតាៈ ស្លាប់យ៉ាងម៉េចទៅ?

ប៉ាន់៖ ស្លាប់ដូចថាមួយបងប្អូនធ្វើការច្រើន តែសម័យនោះយើងប្រាប់គេអត់ជឿទេ គេប្រាប់ថាយើងនិតមាន់អត់ជឿទេ ហើយគេដកទ័ពយើង កាលដកទ័ពហ្នឹងគេឲ្យយើងដើរដឹកដៃគ្នាធ្វើខ្នងទំនប់ ហើយគេដេញវ៉ៃ ដងរែកៗដីណាំដេញវ៉ៃពីក្រោយ ដេញវ៉ៃដូចគោដូចក្របីអញ្ចឹង ។

ធីតា៖ វ៉ៃម៉េច?

ប៉ាន់៖ វ៉ៃដកទ័ពយើង ។ បើអ្នកឯងនិតមាន់រត់អត់រួចទេ ធ្លាក់រមៀលបែកក្បាលហូរឈាម ធ្លាក់ពីជើងទំនប់ទៅបោកនឹងឈើ ខ្ញុំធ្លាប់ឃើញដូចចង្ហឹងខ្សែក្រវ៉ាត់អញ្ចឹងអារៀងឯងនិតមាន់ បើអ្នកឯងពិតប្រាកដទៅអ្នកឯងរួចខ្លួនហើយបើអ្នកឯងក្លែងក្លាយទៅគេចាប់យកទៅវ៉ៃចោលហើយ ។

ធីតា៖ ចុះពូមានបងប្អូនស្លាប់ទេនៅសម័យហ្នឹង?

ប៉ាន់៖ សម័យនោះខ្ញុំមិនមានទេ តែសម័យនោះខ្ញុំជិតស្លាប់ដែរ ជិតស្លាប់ទាំងគ្រួសារ ។

ធីតា៖ ហេតុអីពូ?

ប៉ាន់៖ ព្រោះកាលសម័យនោះយើងជាប់ទិន្នាការ ។

ធីតា៖ ទិន្នាការខាងអី?

ប៉ាន់៖ ទិន្នាការខាងទាហានយើងបម្រើជាតិណាំ ។

ធីតា៖ ទាហានបម្រើជាតិ?

ប៉ាន់៖ បាទ ។

ធីតា៖ ទាហានអីគេ?

ប៉ាន់៖ ទាហានលន់ នល់ ។

ធីតា៖ ទាហានលន់ នល់?

ប៉ាន់៖ បាទ ។ ដែលគេហៅថាទាហានបម្រើជាតិ សម័យនោះគេជ្រើសរើសអ្នកណាធ្វើទាហានគេចាប់វ៉ៃចោលទាំងអស់ ហើយកាលនោះឪពុកខ្ញុំគាត់ធ្វើទាហាន ម្ល៉ោះហើយដល់គេចំរាញ់ជ្រើសរើសទៅឪពុកខ្ញុំនេះគាត់ជាប់ទិន្នាការស័ក្ត៤ ដល់ពេលអញ្ចឹងទៅគេយកគាត់ទាំងគ្រួសារ បងប្អូនកូនចៅមានប៉ុន្មានគេយកទៅវ៉ៃចោលនៅភូមិទ្រាសយើងនេះ ។

ធីតា៖ នៅភូមិទ្រាស?

ប៉ាន់៖ បាទ ។

ធីតា៖ អញ្ចឹងគាត់ស្លាប់នៅក្នុងសម័យហ្នឹង?

ប៉ាន់៖ អត់ទេគាត់ស្លាប់ក្រោយនេះទេ ។

ធីតា៖ ស្លាប់ក្រោយទេ?

ប៉ាន់៖ បាទ ។

ធីតា៖ ប៉ុន្តែយកគាត់ហ្នឹងទៅដាក់នៅភូមិទ្រាស?

ប៉ាន់៖ ចាំមើលខ្ញុំនិយាយហេតុផលឲ្យស្តាប់ គេយកពួកខ្ញុំទៅវៃចោលហ្នឹងគេមិនមែនយកទៅទាំងបន្ទុំចិត្តទេណា៎ គឺគេថានយោបាយឲ្យយើងទៅធ្វើស្រែនៅស្វាយចេក កុំឲ្យយើងបាក់ស្មារតី គេយកយើងទាំងគ្រួសារនេះ គេអត់ឲ្យយើងបាក់ស្មារតីទេ គេរៀបចំគោរទេះ អង្ករល់ រនាស់ឲ្យយើងស្រេច ហើយមានអង្ករ ប្រហុក អំបិល ម្ទេសដាក់ឲ្យយើងទៅធ្វើស្រែនៅស្វាយចេក ។

ធីតា៖ តាមពិតគ្រាន់តែជានយោបាយរបស់គេទេ?

ប៉ាន់៖ បាទ ។ យកទៅសម្លាប់តែកុំឲ្យបងប្អូនតក់ស្លុត ដល់រៀបចំហើយក្នុងភូមិយើងវាប៉ុន្មានគ្រួសារនោះ ដូចជា៣គ្រួសារឬក៏៤គ្រួសារទេជាមួយអ្នកជំលៀសម៉ោពីភ្នំពេញណា៎ ដល់ហើយទៅខ្ញុំទៅភូមិភាគហ្នឹងម៉ោង៨ព្រឹក ទៅដល់ភូមិភាគហ្នឹងមានបងប្អូនយើងធ្វើប្រធានក្រុម ឈ្មោះពេញ ឈ្មោះ ព្រែក តាម៉ូវ ជាអ្នករស់នៅភូមិនេះហើយទៅធ្វើប្រធានក្រុមនៅទ្រាស ម្ហោះហើយគាត់និយាយជាមួយប្រធានសហករណ៍ពីរឿងហេតុផល ហេតុផលដែលពួកខ្ញុំជួយទៅខាងជាតិ ហើយក្រោយពីសម័យយាកកុងខ្ញុំមានគ្រាប់មានកាំភ្លើង មានគេអូជួយទៅខាងនោះនិយាយរឿងហេតុផលនេះទៅបានគេសំលេះគាត់ទៅ ។

ធីតា៖ ម៉េចចឹងពូ?

ប៉ាន់៖ គ្មានអ្នកណាហ៊ាននិយាយទេ ។

ធីតា៖ ម៉េចចឹង?

ប៉ាន់៖ គេផ្អាកគាត់ទុកពិចារណាសិន ។

ធីតា៖ អ្នកណាគេអ្នកផ្អាក?

ប៉ាន់៖ ប្រធានសហករណ៍ ។

ធីតា៖ ប្រធានហ្នឹងឈ្មោះអី?

ប៉ាន់៖ ឈ្មោះ លន់ ។

ធីតា៖ ឥលូវគាត់ហើយមែនទេ?

ប៉ាន់៖ មិនដឹងស្លាប់ឬរស់ទេ ។ បងប្អូនគេនិយាយគេស្តាប់ ដល់ពេលស្តាប់ទៅឲ្យទៅរទេះ៣ ហើយអ្នកភូមិគ្រប់ភូមិយើងទៅគេទៅវៃចោល ខ្ញុំល្ងាចគេឲ្យដេកនៅនោះឯងដល់ព្រឹកឡើងបានគេឲ្យម៉ោវិញ ។

ធីតា៖ ដេកនៅណា?

ប៉ាន់៖ ដេកនៅភូមិទ្រាសយើងហ្នឹង ។

ធីតា៖ ចំនួនរយៈពេលប៉ុន្មាន?

ប៉ាន់៖ រយៈពេលមួយយប់ ។

ធីតា៖ ក្រោយម៉ោធ្វើអីទៀត០០៣ធ

ប៉ាន់៖ ដល់ក្រោយម៉ោទៀតរយៈពេលប៉ុន្មានឆ្នាំចប់បដិវត្តន៍ម៉ោកាលសម័យប៉ុល ពត នោះឪពុកខ្ញុំគាត់ខ្លាចដែរគាត់រត់ ។

ធីតា៖ ចប់បដិវត្តន៍នៅឆ្នាំណា?

ប៉ាន់៖ ឆ្នាំ៧០ប៉ុន្មានទេ ខ្ញុំមិនបានចាប់អារម្មណ៍ទេ ។

ធីតា៖ ៧៣?

ប៉ាន់៖ សម័យដែលចប់ ។

ធីតា៖ ៧៨ហើយអញ្ចឹង បើ៧៥ចូលខ្មែរក្រហមហើយហ្នឹង ។

ប៉ាន់៖ វា៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។

ធីតា៖ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ?

ប៉ាន់៖ បាទ កាលហ្នឹងសម័យប៉ុល ពត ណា៎ ។

ធីតា៖ ចា៎ ។

ប៉ាន់៖ ក្រោយពីចប់យួនចូលម៉ោដឹបូងគាត់ខ្លាចណាស់ សូម្បីតែពួកបរទេសគេចូលម៉ោហ្នឹងក៏គាត់ខ្លាចដែរ គេចូលម៉ោប្រទេសយើងធ្វើសកម្មភាពដូចកាលសម័យប៉ុល ពត គាត់ខ្លាចយួនគាត់រត់ទៅនៅជំរុំថៃ ។

ធីតា៖ អ៎ឪពុកពូហ្នឹងចូលទៅនៅជំរុំថៃទៀត?

ប៉ាន់៖ បាទ ។

ធីតា៖ ហេតុអីបានគាត់រត់ទៅជំរុំ?

ប៉ាន់៖ គាត់ភ័យខ្លួនដូចសម័យប៉ុល ពត គាត់ខ្លាចយួន ។

ធីតា៖ កាលគាត់ទៅហ្នឹងគាត់ទៅតែម្នាក់ឯងទេ?

ប៉ាន់៖ កាលគាត់ទៅហ្នឹងគាត់ទៅជាមួយប្តីប្រពន្ធគាត់ដែរ កាលមុនគាត់ទៅខ្ញុំមិនចង់និយាយរៀបរាប់ទេ ព្រោះវាវែងឆ្ងាយណាស់ ។

ធីតា៖ ពូនិយាយម៉ោព្រោះខ្ញុំមានរីខតសម្រាប់ណូតទុក ។

ប៉ាន់៖ បើនិយាយហេតុផលទៅវាពិបាកណាស់ ។

ធីតា៖ ហើយម៉េចខ្លះគាត់ទៅទាំងប្ដីទាំងប្រពន្ធគាត់មែន?

ប៉ាន់៖ មិនមែននេះទេ ខ្ញុំនិយាយឲ្យអស់ទៅចុះការតស៊ូរបស់គាត់ច្រើនណាស់របស់ឪពុកខ្ញុំ កងទ័ពនៅជុំវិញថៃ យួនចូលម៉ោភ្លាមម៉ោគាត់បង្កើតទ័ពបានដើម្បីការពារទឹកដី ចាប់ពីទាហាន១០នាក់រហូតដល់៣០០០នាក់ គាត់បង្កើតទ័ពនៅជំរុំសាយប៊ី ។

ធីតា៖ គាត់អ្នកបង្កើតនៅហ្នឹងហ្មង?

ប៉ាន់៖ បាទ ៗ គាត់អ្នកដឹកនាំ ៗ មានអាហារពលកម្មសម្រាប់ដោះស្រាយឲ្យកងទ័ពដែលគាត់ចិញ្ចឹមដល់ ហើយទៅបានគាត់ខ្វាចខ្លួនទៅរត់ទៅនៅជាមួយកងទ័ពដល់ទៅនៅជាមួយកងទ័ពទៅបានអាយុ ជិត៨០ ហើយបានគាត់ស្លាប់ ហើយកាលស្លាប់នោះមានបានបងប្អូនណាបានទៅឃើញព្រោះជា សម័យសង្គ្រាម ។

ធីតា៖ សម័យខ្មែរក្រហមមែន?

ប៉ាន់៖ បាទសម័យខ្មែរក្រហម គាត់ស្លាប់នៅលើប្រទេសថៃនេះឯង នៅលើទឹកដីថៃ ។

ធីតា៖ ឪពុកពូស្លាប់នៅលើទឹកដីថៃហ្នឹងហ្មង?

ប៉ាន់៖ បាទ ៗ គាត់ស្លាប់ដោយជំងឺ ។

ធីតា៖ ចុះគាត់ដឹកនាំកងទ័ពឡើង៣០០០នាក់ហើយម៉េចក៏អញ្ចឹង?

ប៉ាន់៖ សម័យសង្គ្រាមវាអញ្ចឹងហើយ ។

ធីតា៖ ចុះខ្មែរក្រហមចូលម៉ោគាត់ទៅធ្វើអីវិញ?

ប៉ាន់៖ ខ្មែរក្រហមម៉ោគាត់មិនបានធ្វើអីទេ តែគាត់ស្លាប់នៅជំរុំហើយ កាលនោះគាត់ចាត់ចែងឲ្យក្មេងធ្វើការ ហើយគាត់ទោនៅជំរុំ ។

ធីតា៖ គាត់ទៅជំរុំនៅឆ្នាំណា?

ប៉ាន់៖ មិនដឹងឆ្នាំប៉ុន្មានទេ ព្រោះខ្ញុំមិនបានចាំផង ដល់ម៉ោទល់សម័យដែលយើងបាននៅក្នុងភ្នំពេញកម្ពុជាហើយតែយើងមិនទាន់បានរៀបចំបក្ស ។

ធីតា៖ កាលយួនចូលហ្នឹង៧៩?

ប៉ាន់៖ ចុង៧៩ ។

ធីតា៖ អញ្ចឹង?

ប៉ាន់៖ បាទ ។

ធីតា៖ ហើយម៉េចបានគាត់រត់អញ្ចឹង?

ប៉ាន់៖ គាត់ខ្លាច ។

ធីតា៖ គាត់ខ្លាច?

ប៉ាន់៖ ព្រោះគាត់ចាស់ហើយ ។

ធីតា៖ គាត់ស័ក្តធំដែរពូ?

ប៉ាន់៖ គ្មានស័ក្តទេសម័យនោះណា៎ សម័យនោះគាត់ថាគាត់អត់មានស័ក្តអីទេ គាត់គ្រាន់តែមានគំនិតមួយធ្វើកងទ័ពដើម្បីការពារទឹកដីយើង ខ្លាចយួននោះវាធ្វើសកម្មភាពខ្លាំង ហើយគាត់បង្កើតកម្លាំងនេះដើម្បីការពាររហូតទាល់តែបានជំរុំមួយជំរុំពី ឪពុកម្តាយខ្ញុំគាត់ខូចហើយ បើឪពុកខ្ញុំគាត់ខូចតាំងពីនៅថៃ ។

ធីតា៖ ម៉េចបានពូដឹងថាគាត់បម្រើកងទ័ព?

ប៉ាន់៖ ចុះខ្ញុំរស់នៅជាមួយគាត់ដែរ ។

ធីតា៖ អញ្ចឹងមានតែពូទៅថៃដែរ?

ប៉ាន់៖ អត់ទេ កាលនេះគាត់បង្កើតនៅនេះណា៎ ភូមិនេះគេជួយដែរណា៎ គេជួយជាអង្ករ ជួយជាអំបិលប្រហុក ជំរុំនៅវាមិនឆ្ងាយទេណា៎នៅខាងកើតព្រៃនេះឯង ។ ដល់បានកម្លាំងច្រើនហើយបានឡើងទៅធ្វើជំរុំនៅខាងនោះ ។

ធីតា៖ គេហៅជំរុំអីគេ?

ប៉ាន់៖ ជំរុំក្បាលរនាស់ ក្បាលរនាស់សាយប៊ី សាយធូណាគេនោះ ។

ធីតា៖ សាយប៊ីអីគេអាហ្នឹង?

ប៉ាន់៖ សាយប៊ីគឺជាពាក្យរបស់ថៃ ។

ធីតា៖ ពូអញ្ចឹងដូចថាពេលខ្មែរក្រហមចូលម៉ោអញ្ចឹងគាត់ធ្វើការធម្មតាទេ?

ប៉ាន់៖ ធ្វើការដូចប្រជាជនធម្មតាទេ ។

ធីតា៖ ធ្វើស្រែធ្វើអីអញ្ចឹងទៅអត់មានធ្វើអីផ្សេងក្រៅពីហ្នឹងទេ?

ប៉ាន់៖ គាត់មិនរករឿងគេទេ ។

ធីតា៖ ដល់ពេលវៀតណាមចូលម៉ោបានគាត់រត់ទៅថៃ?

ប៉ាន់៖ បាទ ។ គាត់ខ្លាចដូចសម័យយើង៧៩ដែលពួកប៉ុល ពតចូលម៉ោហើយវារៀបចំនូវរបបមួយរួចហើយ របបកម្មុនីសគាត់ខ្លាចរបបហ្នឹងបានគាត់រត់ចេញ ។

ធីតា៖ ពូមានស្គាល់មេដឹកនាំខ្មែរក្រហមអៀង សារីអីទេ?

ប៉ាន់៖ អត់ទេឮតែឈ្មោះ ។

ធីតា៖ ធ្លាប់ឮឈ្មោះដល់ហ្នឹងដែរ?

ប៉ាន់៖ ពូពេញប្រទេស អៀង សារី, ប៉ុល ពត, ខៀវ សំផន ។

ធីតា៖ ចុះពូដូចថាអញ្ចឹងគាត់ស្លាប់នៅក្នុងសម័យដឹកនាំទ័ព៣០០០នាក់ហ្នឹងហើយគាត់រត់ទៅថៃ?

ប៉ាន់៖ គាត់រត់ទៅជាមួយកងទ័ពឡើងទៅធ្វើជំរុំបានរយៈពេល២,៣ឆ្នាំបានគាត់ស្លាប់ ។

ធីតា៖ កាលហ្នឹងគាត់អត់មានវ៉ៃជាមួយទាហានខ្មែរក្រហមទេ?

ប៉ាន់៖ អត់មានវ៉ៃទេ ។

ធីតា៖ វ៉ៃជាមួយទាហានវៀតណាម?

ប៉ាន់៖ បាទវ៉ៃជាមួយទាហានវៀតណាម ។ វ៉ៃជាមួយខ្មែរក្រហមណាបើខ្មែរក្រហមវាអស់ហើយហ្នឹងវារត់ទៅតាមព្រំដែនអស់ហើយ ។

ធីតា៖ ហេតុអីបានជាគាត់វ៉ៃជាមួយទាហានវៀតណាមវិញ?

ប៉ាន់៖ កាលនោះយើងវ៉ៃដោយសារតែយើងដឹកនាំចង់បានកម្លាំងទ័ពដើម្បីបង្កើតនៅតាមព្រំដែន ។

ធីតា៖ ការពារព្រំដែនហ្នឹង?

ប៉ាន់៖ បាទ ។

ធីតា៖ កាលហ្នឹងគាត់អាយុប៉ុន្មានហើយ?

ប៉ាន់៖ អាយុ៧៨ហើយ ។

ធីតា៖ កាលដែលគាត់ដឹកនាំណា៎?

ប៉ាន់៖ បាទកាលហ្នឹង៧៨ឆ្នាំ ។

ធីតា៖ ហើយដឹកនាំហ្នឹងម៉េចខ្លះទៅ ដូចថាការពារព្រំដែនហ្នឹងម៉េចខ្លះទៅ សកម្មភាពនៅក្នុងព្រឹត្តិការណ៍ហ្នឹង?

ប៉ាន់៖ អារឿងហ្នឹងខ្ញុំមិនសូវដឹងទេព្រោះខ្ញុំនៅឆ្ងាយណាស់ ។

ធីតា៖ ចុះពូបែកគាត់តាំងពីពេលណា?

ប៉ាន់៖ ខ្ញុំបែកតាំងពីសម័យវៀតណាមចូលម៉ោបានមួយឆ្នាំបានបែក បែកគ្នារហូត ។

ធីតា៖ វៀតណាមចូលស្រុក?

ប៉ាន់៖ បាទ ។

ធីតា៖ អញ្ចឹងគាត់ស្លាប់នៅក្នុងឆ្នាំណា?

ប៉ាន់៖ មិនដឹងឆ្នាំណាទេ ។ ព្រោះកាលគាត់ខូចដឹងតាមរយៈគេទៅម៉ោទេ ។

ធីតា៖ ដឹងតាមរយៈដែលគេត្រលប់ម៉ោវិញមែន?

ប៉ាន់៖ បាទ ។ មិនដែលបានថែរក្សាគាត់ពេលគាត់ឈឺគាត់ស្លាប់នោះទេព្រោះកាលសម័យនោះវាតឹង ។

ធីតា៖ សម័យអីគេ?

ប៉ាន់៖ សម័យវាតឹង ។

ធីតា៖ វាតឹងរឹង?

ប៉ាន់៖ បាទកងពលនៅតាមព្រំដែន ។

ធីតា៖ ពេលបែកវៀតណាមហើយនៅមានការតឹងរឹងទៀត?

ប៉ាន់៖ កាលវៀតណាមចូលម៉ោមានពួកវៀតណាមជុំវិញប្រទេសកម្ពុជា តាមព្រំដែនវៀតណាម ។

ធីតា៖ នៅតាមព្រំដែនហ្នឹងនៅស្រុកអីគេដែរ?

ប៉ាន់៖ វាពិបាកនិយាយស្រុកភូមិណាស់ ។

ធីតា៖ ប្រកប៉ោយប៉ែតឬក៏ប្រកខាង..?

ប៉ាន់៖ ប្រកខាងភូមិអំពិលណ៎ា អំពិលពងទឹកយើងនេះណ៎ា ។

ធីតា៖ ភូមិអំពិល?

ប៉ាន់៖ បាទ ។

ធីតា៖ ពូមានដឹងឃុំអីស្រុកអីគេទេ?

ប៉ាន់៖ ស្រុកឧត្តមានជ័យ ។

ធីតា៖ កាលពីមុន?

ប៉ាន់៖ ពីមុនស្រុកថ្មពួក ។

ធីតា៖ បើពូនៅតែខាងកងកុមារទេ អត់ដឹងទេ?

ប៉ាន់៖ ខ្ញុំនៅខាងយុទ្ធជនទេ ។

ធីតា៖ នៅខាងយុទ្ធជន?

ប៉ាន់៖ បាទ ។

ធីតា៖ ចុះម្ដាយពូវិញ?

ប៉ាន់៖ ម្ដាយខ្ញុំនៅខាងត្បាញសូត្រ អំបោះ ក្រមា ។

ធីតា៖ អ៎ ។

ប៉ាន់៖ និយាយទៅសម័យនោះវេទនាណាស់ មើលទៅថ្មីៗហើយបាត់ថ្ងៃនេះស្អែក ខ្ញុំអាណោចអាធម ណាស់ មិនចង់នឹកដល់ទេ ឲ្យតែនឹកដល់ហ្នឹងវាឆ្អែតព្រោះធ្លេចភ្នែកទៅវាឃើញ ឃើញបងប្អូនវាវេទនាពេក ។

ធីតា៖ តែអត់មានស្លាប់មានអីទេ?

ប៉ាន់៖ មានប្រជាជនយើងនៅក្នុងភូមិនេះវាស្លាប់ដែរ តែវាតិចណាស់ព្រោះមានការយោគយល់គ្នាច្រើន ហើយស្លាប់ដោយសារប្រជាជនវាថ្មីៗហើយនៅឆ្ងាយៗ វាស្លាប់ដោយសារដាច់បាយវាហូបអត់គ្រប់គ្រាន់ ដូបបបរឲ្យតែម្នាក់មួយចានទេណាស់ ។

ធីតា៖ ចុះពេលបែកហើយពូទៅនៅជាមួយអ្នកណាគេវិញ?

ប៉ាន់៖ នៅក្នុងភូមិ ។

ធីតា៖ នៅក្នុងភូមិហ្នឹងនៅជាមួយគ្រួសារខាងណា?

ប៉ាន់៖ នៅខាងម្ដាយ ។

ធីតា៖ ពេលវៀតណាមចូលម៉ោគ្រាប់កាំភ្លើងពុំពីខាងណាម៉ោវិញ?

ប៉ាន់៖ មិនដឹងពុំខាងណាបើពុំតែភូមិហ្នឹងឯង ។

ធីតា៖ កន្លែងហ្នឹងគេហៅតំបន់ខ្លាំងមែន?

ប៉ាន់៖ ខ្មែរក្រហមបាញ់គ្នាជាមួយប៉ាវ៉ាក៏នៅហ្នឹង ។

ធីតា៖ ខ្មែរក្រហមបាញ់គ្នាជាមួយប៉ាវ៉ានៅក្នុងភូមិហ្នឹងច្រើនដែរ?

ប៉ាន់៖ ពួកក្មេងៗមិនដែលបានចេញពីរន្ធទេ នៅតែក្នុងរន្ធដូចក្ដាមហ្នឹងឯង ប្រវត្តិភូមិនេះលំបាកណាស់ ។

ធីតា៖ ទាហានប៉ាវ៉ាខាងណាវិញ?

ប៉ាន់៖ ទាហានប៉ាវ៉ាខាងព្រៃហ្នឹងឯង ។

ធីតា៖ ឈ្មោះអីគេទៅ មានដឹងថាមេក្រុមណាអ្នកដឹកនាំទេ?

ប៉ាន់៖ ខ្ញុំមិនបានទៅដឹងអារឿងហ្នឹងទេ វាស្គាល់ដូចថាយើងស្គាល់សេះស្គាល់ដំរីណាស់ ។

ធីតា៖ ចាស ។

ប៉ាន់៖ ស្គាល់ដូចថាវាមិនបានជិតដិត ពុំតែគេម៉ោយើងចេះតែស្គាល់គេទៅណាស់ ។

ធីតា៖ ចាស ។

ប៉ាន់៖ បើឲ្យទៅស្គាល់ប្រវត្តមេកង មេភូមិ មេក្រុមគេហ្នឹងក៏វាមិនស្គាល់ដែរ ។

ធីតា៖ ចាស ។

ប៉ាន់៖ ព្រោះយើងរស់នៅក្នុងភូមិ ។

ធីតា៖ ចាស ។ ចុះពីយល់ឃើញម៉េចក្រោយសម័យ៧៩ហើយ យល់ឃើញទិដ្ឋភាពក្រោយសម័យ៧៩ហ្នឹង យ៉ាងម៉េច?

ប៉ាន់៖ ក្រោយ៧៩ម៉ោពេលចប់សង្គ្រាមអស់ នឹកឃើញដល់សព្វថ្ងៃវាខុសគ្នា ។

ធីតាៈ ខុសគ្នាយ៉ាងម៉េច?

ប៉ាន់ៈ ខុសគ្នាត្រង់ថាសម័យនេះវាមានសិទ្ធ ហើយសម័យនោះវាអត់មានសិទ្ធទេ ចង់គេម៉ោធ្វើបាបក៏ស្រេចតែគេ ចង់គេម៉ោប្រើយើងក៏ស្រេចតែគេ គេយកយើងទៅបាញ់ចោលក៏ស្រេចតែគេ អាហ្នឹងបានន័យថាយើងអត់មានសិទ្ធ ហើយសព្វថ្ងៃយើងមានសិទ្ធទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង អ្នកឯងប្រើសម បើអ្នកឯងប្រើមិនសមក៏អ្នកឯងមិនហ៊ានប្រើគេដែរ អញ្ចឹងបានថាសព្វថ្ងៃវាខុសគ្នាច្រើន សម័យគេជឿនលឿន ហើយសម័យខ្ញុំដឹងតែលំបាក ខ្ញុំលំបាកតាំងពីខ្ញុំអាយុ១២ម៉ោម្ល៉េះរហូតទាល់ឈប់សង្គ្រាម ។

ធីតាៈ តែពូអត់មានបានចូលធ្វើសង្គ្រាមទេ?

ប៉ាន់ៈ ខ្ញុំមិនបានធ្វើទេ តែខ្ញុំដើរតាមឪពុក ។

ធីតាៈ ដើរតាមឪពុកហ្មង?

ប៉ាន់ៈ បាទ ។

ធីតាៈ ដើរតាមរហូតហ្មង?

ប៉ាន់ៈ ដើរតាមរហូត ។

ធីតាៈ ទើបតែម៉ោបែកពេល...?

ប៉ាន់ៈ ទើបតែបែកពេលសម័យវៀតណាមចូល ។

ធីតាៈ ពេលវៀតណាមចូល៧៩?

ប៉ាន់ៈ បាទ ។

ធីតាៈ អញ្ចឹងពេល៧៩?

ប៉ាន់ៈ វៀតណាមចូល ។ ហើយបានចូលថៃ

ធីតាៈ ហើយហេតុអីបានជាគាត់សម្រេចចិត្តឲ្យពូម៉ោនេះហើយគាត់ទៅថៃ?

ប៉ាន់ៈ ព្រោះខ្ញុំរស់នៅតែក្នុងភូមិហ្នឹង ហើយពីដើមខ្ញុំរស់នៅតែជាមួយគាត់នៅបាក់ទ្រាកំពង់ចម្លងនៅភ្នំពេញហ្នឹង អាហ្នឹងគេហៅសម័យរាស្ត្រនិយមណ៎ ។

ធីតាៈ ចា៎ ។

ប៉ាន់ៈ កាលនោះខ្ញុំអាយុ១២ឆ្នាំ ។

ធីតាៈ កាលសម័យខ្មែរក្រហមត្រឹមតែ១០ជាងទេ?

ប៉ាន់ៈ បាទ១៥ឆ្នាំ ។

ធីតាៈ ចុះពូមានដែលដឹងពីរឿងតុលាការឿងអីទេ?

ប៉ាន់៖ គ្មានតុលាការទេសម័យនោះ ស្រេចស៊ីសងដូចថានៅចំណោមអ្នកទាំងអស់គ្នាបើគេស្រលាញ់នាង នាងរស់បើគេស្អប់នាងនាងមិនបានរស់ទេ ។

ធីតា៖ អ៊ំ ។

ប៉ាន់៖ គេចន្ទុលតែប៉ុណ្ណេះនាងឯងស្លាប់ មិនបាច់ពិបាកនិយាយ អត់មានសិទ្ធតវ៉ា អត់មានសិទ្ធថាប្រកែកអីទេ ។ បើនាងឯងមានគេស្រលាញ់ច្រើនទោះបីនាងឯងខុសបន្តិចបន្តួចក៏គេឲ្យនាងឯងរស់ដែរ តែបើមានគេស្អប់តែពីឬបីនាក់គឺចប់ហើយ ។

ធីតា៖ ភូមិនេះទើបតែកកើតតើមែនទេ?

ប៉ាន់៖ កើតយូហើយ ។

ធីតា៖ តាំងពីឆ្នាំណា?

ប៉ាន់៖ មិនដឹងទេ តាំងពីខ្ញុំកើតដឹងក្តីម៉េះម្ល េះ ពីដើមឡើយនៅភូមិខាងកើត ខាងកើតដែលដាក់សាលារៀនហ្នឹង ។

ធីតា៖ សាលារៀនអីគេ សាលារៀនដែលគាពិនបង្រៀនហ្នឹងមែន?

ប៉ាន់៖ ហ្នឹងអើយអាសាលារៀនយើងខាងកើតនេះ ។ សាលារៀនភូមិនេះឯងគ្រាន់ថាវានៅចុងខាងកើត កាលមុនភូមិចាស់នៅខាងហ្នឹង វាមិនច្រើនទេកាលនោះភូមិប្រហែលជាខ្ទង់៣០អីហ្នឹង ។

ធីតា៖ ចុះសព្វថ្ងៃពូប្រកបមុខរបរអីគេដែរ?

ប៉ាន់៖ ខ្ញុំប្រជាជនធម្មតា ។

ធីតា៖ ធ្វើស្រែធ្វើអីអញ្ចឹងទៅ?

ប៉ាន់៖ បាទ ។

ធីតា៖ មានកូនប៉ុន្មាននាក់?

ប៉ាន់៖ មានកូន៨នាក់ ។

ធីតា៖ កូន៨នាក់?

ប៉ាន់៖ បាទ សម័យនោះអត់មានអីកាត់បន្ថយ ។

ធីតា៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ប៉ាន់៖ ស្រី៣ ប្រុស៥ ។

ធីតា៖ ចុះពូជាកូនទីប៉ុន្មាន?

ប៉ាន់៖ ខ្ញុំជាកូនទី៤ ។

ធីតាៈ ហើយបងប្អូនពូមានប៉ុន្មាននាក់?

ប៉ាន់ៈ មាន៦នាក់ ។

ធីតាៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ប៉ាន់ៈ ស្រី១ ។

ធីតាៈ ប្រុស៥?

ប៉ាន់ៈ បាទ ។

ធីតាៈ ពូកូនទីប៉ុន្មាន?

ប៉ាន់ៈ កូនទី៤ ។

ធីតាៈ អញ្ចឹងឪពុកម្តាយពូស្លាប់អស់ហើយណោះ?

ប៉ាន់ៈ ស្លាប់អស់ហើយ ។

ធីតាៈ តាំងពីសម័យខ្មែរក្រហមមែន?

ប៉ាន់ៈ បាទ ។ ហើយខ្ញុំមានបងធ្វើប្រធានភូមិ ។

ធីតាៈ ប្រធានភូមិនៅហ្នឹងមែន?

ប៉ាន់ៈ បាទ ។

ធីតាៈ អរគុណច្រើនពូ ។

ប៉ាន់ៈ បាទ ។

«ចប់»